# ប្រជាមតិស្តីពីសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait

ប្រជាជនអូស្ត្រាលីមកពីទឹកដីជាច្រើន អនុវត្តជំនឿជាច្រើន និងនិយាយភាសាជាច្រើនផងដែរ។ ជនជាតិដើម និងអ្នកដីកោះ Torres Strait គឺជាប្រជាជនដំបូងគេនៃប្រទេសអូស្ត្រាលី ហើយបានរស់នៅទីនេះជាង 65,000 ឆ្នាំមកហើយ។កំប៉ុន្តែ រដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលីមិនទទួលស្គាល់ឋានៈពិសេសរបស់ពួកគេទេ។ ហេតុដូច្នេះហើយនៅចុងឆ្នាំនេះ យើងនឹងអាចពិចារណាដើម្បីកែប្រែរដ្ឋធម្មនុញ្ញរបស់យើងតាមរយៈការធ្វើប្រជាមតិ។
ប្រជាជនអូស្ត្រាលីទាំងអស់នឹងមានឱកាសទទួលស្គាល់សិទ្ធិនានារបស់ ជនជាតិដើម និងអ្នកដីកោះ Torres Strait នៅក្នុងរដ្ឋធម្មនុញ្ញរបស់យើងតាមរយៈ សំឡេងមួយដែលនឹងធានាថាពួកគេត្រូវបានគេស្តាប់ឮ អំពីបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។។

## តើអ្វីទៅសេចក្តីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart)?

នៅខែឧសភា ឆ្នាំ2017 ប្រជាជនជាតិដើម និងអ្នកដីកោះ Torres Strait ជាង 250 នាក់បានចេញសេចក្តីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart)។ វាស្នើសុំឱ្យយើងបង្កើតអនាគតដ៏ល្អប្រសើរមួយសម្រាប់ប្រទេសអូស្ត្រាលីទាំងមូល ហើយដាក់បញ្ចូលសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait នៅក្នុងរដ្ឋធម្មនុញ្ញអូស្ត្រាលី។

## តើអ្វីទៅសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait?

សំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait គឺជាមធ្យោបាយមួយសម្រាប់ ប្រជាជនជាតិដើម និងអ្នកដីកោះ Torres Strait ដើម្បីណែនាំរដ្ឋាភិបាលអំពីច្បាប់ និងគោលនយោបាយនានាដែលប៉ះពាល់ដល់ពួកគេ។

## តើប្រជាមតិជាអ្វី?

ប្រជាមតិគឺជាពេលណាអ្នកបោះឆ្នោតត្រូវបានស្នើសុំឱ្យឆ្លើយ បាទ/ចាស ឬទេ ទៅនឹងសំណួរមួយ ឬសំណួរនានា។មធ្យោបាយតែមួយគត់ដើម្បីកែប្រែរដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលីគឺតាមរយៈការធ្វើប្រជាមតិ។

## តើនរណាអាចបោះឆ្នោតប្រជាមតិ?

មានតែប្រជាជនដែលបានចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ អាចចូលរួមក្នុងការធ្វើប្រជាមតិ។ការបោះឆ្នោតប្រជាមតិគឺជាកាតព្វកិច្ច សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះ។

## តើខ្ញុំបោះឆ្នោតប្រជាមតិដោយរបៀបណា?

ការធ្វើប្រជាមតិគឺដូចគ្នានឹងការបោះឆ្នោតជ្រើសតាំងដែរ។នៅថ្ងៃបោះឆ្នោត អ្នកអាចទៅកន្លែងបោះឆ្នោតមួយ ហើយបោះឆ្នោតរបស់អ្នកនៅលើសន្លឹកឆ្នោតមួយ។

## តើការធ្វើប្រជាមតិត្រូវបានគេសម្រេចដោយរបៀបណា?

ដើម្បីឱ្យប្រជាមតិទទួលបានជោគជ័យ វាត្រូវការសំឡេងភាគច្រើនពីរកម្រិត។នេះមានន័យថា សំឡេងសន្លឹកឆ្នោតភាគច្រើនយ៉ាងហោចណាស់បួនរដ្ឋ និងនៅទូទាំងប្រទេសអូស្ត្រាលីទាំងមូល។

## តើការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកជីកោះ Torres Strait នឹងធ្វើឡើងនៅពេលណា?

ការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកជីកោះ Torres Strait នឹងធ្វើឡើងនៅចុងឆ្នាំនេះ។

## តើការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកជីកោះ Torres Strait នឹងសួរសំណួរអ្វីខ្លះ?

"ច្បាប់ដែលបានស្នើឡើង៖ ដើម្បីកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ប្រជាជនដំបូងនៃប្រទេសអូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម និងអ្នកជីកោះ Torres Strait។ អ្នកយល់ព្រមលើការកែប្រែដែលបានស្នើឡើងនេះទេ?

## តើនរណាបង្កើតសន្លឹកព័ត៌មាននេះ?

សន្លឹកព័ត៌មាននេះបានបង្កើតឡើងដោយកិច្ចខិតខំប្រឹងប្រែងរួម របស់ Life Without Barriers, Reconciliation Australia, SNAICC – National Voice for our children, the Yes Alliance និង Polaron Language Services ពជាដៃគូនេះត្រូវបានបង្កើតឡើងដើម្បីជួយបង្កើតព័ត៌មានដែលអាចចូលដំណើរការបានស្តីពីសំឡេងជនជាតិដើម និងអ្នកជីកោះ Torres Strait។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅឯណា?

The National Indigenous Australians Agency www.niaa.gov.au
SNAICC National Voice for our Children www.snaicc.org.au
Reconciliation Australia www.reconciliation.org.au
First Peoples Disability Network www.fpdn.org.au
Life Without Barriers www.lwb.org.au
Yes 23 www.yes23.com.au
Polaron www.polaron.com.au
Have Your Say www.haveyoursay.net